N.15
23.4.02

# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ


០៩-៤-២០០២ -ព្រះរាជក្រឹត្យ នស/រកត/ ០៤០២/០៩៨ ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ទោ-ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈចំពោះសព:

១- ឧត្តមសេនីយ៍ត្រី **សែន ចំរុង**

២- ឧត្តមសេនីយ៍ត្រី **កែ ពក**

៣- វរសេនីយ៍ឯក **គឹម គៀ** ៩៩៣

១៨-៤-២០០២ -ព្រះរាជក្រឹត្យ នស/រកត/ ០៤០២/១០២ ស្តីពីការផ្តល់សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ជូនលោក **ឌុយអែរស ហ្សង់ក្លូត** (JEAN-CLAUDE DHUEZ )សញ្ជាតិដើមបារាំង ៩៩៤

១៨-៤-២០០២ -ព្រះរាជក្រឹត្យ នស/រកត/ ០៤០២/១០៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **គង់ ជិនជុយ** ( KONG CHIN CHU) សញ្ជាតិដើមចិន ៩៩៥

១៨-៤-២០០២ -ព្រះរាជក្រឹត្យ នស/រកត/ ០៤០២/១០៤ ស្តីពីការតែងតាំងលោក **ហេង ជី** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ៩៩៦


## II- រាជរដ្ឋាភិបាល

### ១_ អនុក្រឹត្យ


២២-៤-២០០២ - អនុក្រឹត្យលេខ ៣២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៩៩៧

២២-៤-២០០២ - អនុក្រឹត្យលេខ ៣៣ អនក្រ.បក ស្តីពីការគ្រប់គ្រងគ្រឿងសំអាង ៩៩៩

២៣-៤-២០០២ - អនុក្រឹត្យលេខ ៣៤ អនក្រ.បក ស្តីពីការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ ១០០៤

២៣-៤-២០០២ - អនុក្រឹត្យលេខ ៣៥ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ ១០០៨

១៩-៤-២០០២ - អនុក្រឹត្យលេខ ១៩៥ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ១០១៣

១៩-៤-២០០២ - អនុក្រឹត្យលេខ ១៩៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១០១៤

15.



១៩-៤-២០០២ - អនុក្រឹត្យលេខ ១៩៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០១៥
១៩-៤-២០០២ - អនុក្រឹត្យលេខ ១៩៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១០១៦
១៩-៤-២០០២ - អនុក្រឹត្យលេខ ១៩៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១០១៨
១៩-៤-២០០២ - អនុក្រឹត្យលេខ ២០០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១០១៩
១៩-៤-២០០២ - អនុក្រឹត្យលេខ ២០១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០២០
១៩-៤-២០០២ - អនុក្រឹត្យលេខ ២០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០២១
១៩-៤-២០០២ - អនុក្រឹត្យលេខ ២០៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០២២
២៣-៤-២០០២ - អនុក្រឹត្យលេខ ២០៤ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ១០២៣
២៣-៤-២០០២ - អនុក្រឹត្យលេខ ២០៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១០២៤

## ២_សេចក្តីសំរេច

១៩-៤-២០០២ -សេចក្តីសំរេចលេខ ២៥ សសរ ស្តីពីការបង្កើតគណៈកម្មការទប់ស្កាត់ការធ្វើអន្តោប្រវេសន៍ ខុសច្បាប់នៅខេត្ត រតនគិរី-មណ្ឌលគិរី និងខេត្តក្រចេះ ១០២៦

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/០៩៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១**: តម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជាកិច្ចបច្ឆាមរណៈចំពោះសព :

១- ឧត្តមសេនីយ៍ត្រី សែន ចំរុង អត្តលេខ ០០០០៨៧ ទីប្រឹក្សាក្រសួងការពារជាតិ ។

២- ឧត្តមសេនីយ៍ត្រី កែ ពក អត្តលេខ ០០៤៣៤៨ ទីប្រឹក្សាក្រសួងការពារជាតិ ។

**មាត្រា ២**: តម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈចំពោះសព :

- វរសេនីយ៍ឯក គឹម គៀ អត្តលេខ ០០០៧៣៦ នាយករងទីចាត់ការផែនការ អគ្គបញ្ជាការដ្ឋាន ។

**មាត្រា ៣**: នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤**: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ៧៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ពរល. ០២.០៤.០០១០៩

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០២

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/១០២

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ ជូនលោក ឌុយអែរស ហ្សង់ក្លូត ( Jean-Claude DHUEZ ) សញ្ជាតិដើមបារាំង កើតថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ១៩៦៥ នៅអាមីញៀង នៃសាធារណរដ្ឋបារាំង ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

៣រល-០៤.០៤.០០១១២

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២

លេខ: ៩០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/១០៣

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **គង់ ជិនជុយ** ( KONG CHIN CHU ) សញ្ជាតិដើមចិន កើតថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៤០ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខៈ ៩៦ ច.ល

ដើម្បីចម្លងចែក

៣៤-៤-០៤-០០១១៣

ធ្វើនៅព្រះបរមរាជវាំង,រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/១០៤

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** តែងតាំងឯកឧត្តម **ហេង ឌី** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ: ៩៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ៤ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈឹម តាន់**

ទរល.០២.០៤.០០១១៤

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

**********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២, ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២០,០០០ លានរៀល ( ម្ភៃពាន់លានរៀលគត់ ) ពីជំពូក ១២ ( ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១២ ( ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ឧបត្ថម្ភមូលនិធិឃុំ សង្កាត់ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
រដ្ឋមន្ត្រីស្តីទី

អ៊ុក រ៉ាប៊ុន

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រង គ្រឿងសំអាង

***********

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងឱសថ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីអំពីការគ្រប់គ្រង គុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និង សេវា

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០២

# សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រងគ្រឿងសំអាងគ្រប់ប្រភេទ ដែលធ្វើអាជីវកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានា គុណភាព និង សុវត្ថិភាពដល់អ្នកប្រើប្រាស់ ។

**មាត្រា ២.-**

គ្រឿងសំអាង គឺជាផលិតផល ដែលផ្សំឡើងដោយសារធាតុគីមី ជីវផលិតផល រុក្ខជាតិ ឬសិលាជាតិសំរាប់ ប្រើប្រាស់ក្នុងការការពារ ថែរក្សា សំអាត ឬ សំអាង ផ្នែកណាមួយនៃរាងកាយមនុស្ស ដើម្បី ឱ្យកាន់តែមានសោភ័ណភាព តាមវិធី ផាត់ លាប រិត ត្រាំ ម៉ាស្សា ឬ តាមវិធីណាមួយផ្សេងទៀត ។

**មាត្រា ៣.-**

គ្រឿងសំអាង មានជាអាទិ៍ផលិតផល :

- ប្រើលើសក់
- ប្រើលើស្បែក
- ប្រើលើក្រចក
- អនាម័យមាត់ ធ្មេញ និង ខ្លួនប្រាណគ្រប់ប្រភេទ
- ទឹកអប់និងគ្រឿងក្រអូបប្រហាក់ប្រហែល ។

## ជំពូកទី ២

## ប្រភេទ នៃគ្រឿងសំអាង

**មាត្រា ៤.-**

គ្រឿងសំអាងចែកជា២ប្រភេទ :

-ប្រភេទ១ : គ្រឿងសំអាង ផ្សំឡើងដោយសារធាតុគីមីដែលស្ថិតក្នុងបញ្ជីកំរិតកំណត់របស់ក្រសួងសុខាភិបាល និងគ្រឿងសំអាងដែលប្រើជុំវិញរង្វង់ភ្នែក បបូរមាត់ និងប្រើលើជាលិកាទន់ ។

បញ្ជីឈ្មោះសារធាតុសកម្ម និងសារធាតុរួមផ្សំ ព្រមទាំងកំរិតកំណត់របស់សារធាតុនិមួយៗដែលអនុញ្ញាតឱ្យប្រើក្នុងផលិតកម្មគ្រឿងសំអាង និង បញ្ជីឈ្មោះសារធាតុហាមឃាត់ក្នុងផលិតកម្មគ្រឿងសំអាង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

-ប្រភេទ២ : គ្រឿងសំអាងដែលមិនស្ថិតក្នុងប្រភេទ១ ។

**មាត្រា ៥.** _

គ្រឿងសំអាងក្លែងបន្លំ ឬ ក្លែងក្លាយ គឺជា :

-គ្រឿងសំអាងដែលផលិតដោយគ្មានសារធាតុសកម្ម ឬសារធាតុផ្សំមិនគ្រប់ចំនួន ឬមិនត្រឹមត្រូវតាមសមាសធាតុផ្សំដែលផលិតករបានរៀបរាប់ដោយផលិតករបានចុះក្នុងឯកសារតម្កល់នៅក្រសួងសុខាភិបាល ពេលចុះ បញ្ជិកា ។

-គ្រឿងសំអាងដែលមានកំរិតជាតិសកម្មតិចជាង៨០% នៃកំរិតជាតិសកម្មកំណត់នៅក្នុងឯកសារឬលើប្រអប់ ។

## ជំពូកទី ៣
## បែបបទ និង លក្ខខ័ណ្ឌក្នុងការសុំចុះបញ្ជិកា

**មាត្រា ៦.** _

គ្រឿងសំអាងដែលនាំចូលសំរាប់ធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែបានទទួលវិញ្ញាបនប័ត្របញ្ជិកាពីក្រសួងសុខាភិបាល ។ វិញ្ញាបនប័ត្របញ្ជិកាមានសុពលភាពរយៈពេល៥ឆ្នាំ ។

ចំពោះផលិតផលក្នុងស្រុកជាសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

**មាត្រា ៧.** _

ក្រសួងសុខាភិបាលមានសិទ្ធិដកហូតវិញ្ញាបនប័ត្របញ្ជិកាវិញ ក្នុងករណីគ្រឿងសំអាងនោះ :

ក-បានបង្កគ្រោះថ្នាក់ ដល់អ្នកប្រើប្រាស់

ខ-មានគុណភាពក្លែងបន្លំ ឬ មិនត្រឹមត្រូវតាមឯកសារផលិត ដែលបានតម្កល់នាពេលសុំចុះបញ្ជិកានៅក្រសួងសុខាភិបាល ។

## ជំពូកទី ៤
## បែបបទ អាជីវកម្ម និង ពាណិជ្ជកម្មគ្រឿងសំអាង

**មាត្រា ៨.-**

គ្រឿងសំអាងអាចតាំងលក់ក្នុងគ្រឹះស្ថានលក់ឱសថ ឬ គ្រឹះស្ថានលក់គ្រឿងសំអាង ដែលមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។ ចំពោះការលក់រាយនៅតាមទីកន្លែងនានា ដូចជាតូប ឬ រានលក់ឥវ៉ាន់តូចតាច មិនតម្រូវឱ្យមានការអនុញ្ញាតពីក្រសួងសុខាភិបាលទេ ប៉ុន្តែមន្ត្រីសុខាភិបាលអាចត្រួតពិនិត្យនូវផលិតផលទាំងនោះ ដើម្បីធានានូវសុវត្ថិភាពសាធារណៈ ។

**មាត្រា ៩.-**

ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល :

១-បែបបទនិងល័ក្ខខ័ណ្ឌក្នុងការសុំចុះបញ្ជិកាគ្រឿងសំអាង

២-បែបបទនិងល័ក្ខខ័ណ្ឌក្នុងការសុំបើកគ្រឹះស្ថានអាហារ័ណ នីហារ័ណគ្រឿងសំអាង

៣-បែបបទ និង ល័ក្ខខ័ណ្ឌ ក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងសំអាង

## ជំពូកទី ៥
## សមត្ថកិច្ចក្នុងការគ្រប់គ្រង

**មាត្រា ១០.-**

ភ្នាក់ងារត្រួតពិនិត្យក្រសួងសុខាភិបាលដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិ :

-ចុះត្រួតពិនិត្យ និង ណែនាំការអនុវត្តន៍លិខិតបទដ្ឋាន ដែលពាក់ព័ន្ធនឹងគ្រឿងសំអាងនៅតាមគ្រឹះស្ថានអាហារ័ណ នីហារ័ណ និង អគារលក់គ្រឿងសំអាង

-ស្រង់យកគ្រឿងសំអាងគំរូសំរាប់ធ្វើការវិភាគគុណភាពក្នុងករណីចាំបាច់ រាប់ទាំងគ្រឿងសំអាងដែលផលិតក្នុងស្រុក

-ឃាត់ទុកបណ្តោះអាសន្នវត្ថុតាង ដែលមានការសង្ស័យជាបទល្មើស និងរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១២.-

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្ត អនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ០៤ ៗ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួលៈ

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ១២

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង ប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

**សំរេច**

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅបំពេញបន្ថែមព្រះរាជក្រឹត្យ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សដូចមានចែងក្នុងជំពូកទី២ ស្តីពីប្រាក់បំណាច់មុខងារ ។

**មាត្រា ២.-**

អនុក្រឹត្យនេះ កំណត់ការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការដែលមានមុខតំណែងជា ប្រធាននាយកដ្ឋាន អភិបាលរងខេត្ត-ក្រុង អធិការថ្នាក់កណ្តាល ព្រឹទ្ធបុរសមហាវិទ្យាល័យ អភិបាលស្រុក-ខ័ណ្ឌ ហើយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន និងកំណត់បន្ថែម ប្រាក់កំរៃគរុកោសល្យរបស់មន្ត្រីរាជការ ក្នុងវិស័យអប់រំ ។

## ជំពូកទី ២
## ប្រាក់បំណាច់មុខងារ

**មាត្រា ៣.-**

មន្ត្រីរាជការស៊ីវិល ដែលមានមុខតំណែងជា ប្រធាននាយកដ្ឋាន អភិបាលរងខេត្ត-ក្រុង អធិការថ្នាក់កណ្តាល ព្រឹទ្ធបុរសមហាវិទ្យាល័យ អភិបាលស្រុក-ខ័ណ្ឌ ហើយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័នថ្នាក់កណ្តាល ត្រូវបានទទួលប្រាក់បំណាច់មុខងារប្រចាំខែ ដូចមានចែងនៅក្នុងតារាងខាងក្រោមនេះ :

| ល.រ | មុខងារ | កំរិត ទី៥ | កំរិត ទី៤ | កំរិត ទី៣ | កំរិត ទី២ | កំរិត ទី១ |
|---|---|---|---|---|---|---|
| ១ | ប្រធាននាយកដ្ឋាន | ៦២០ ០០០ ៛ | ៦៥៨ ០០០ ៛ | ៦៩៨ ០០០ ៛ | ៧៤១ [illegible]០០ ៛ | ៧[illegible] ០០០ ៛ |
| ២ | អភិបាលរង ខេត្ត-ក្រុង | ៦១៥ ០០០ ៛ | ៦៥៣ ០០០ ៛ | ៦៩៣ ០០០ ៛ | ៧៣៦ ០០០ ៛ | ៧៨១ ០០០ ៛ |
| ៣ | អធិការថ្នាក់កណ្តាល | ៦១០ ០០០ ៛ | ៦៤៨ ០០០ ៛ | ៦៨៨ ០០០ ៛ | ៧៣១ ០០០ ៛ | ៧៧៦ ០០០ ៛ |
| ៤ | ព្រឹទ្ធបុរសមហាវិទ្យាល័យ | ៦០៥ ០០០ ៛ | ៦៤៣ ០០០ ៛ | ៦៨៣ ០០០ ៛ | ៧២៦ ០០០ ៛ | ៧៧១ ០០០ ៛ |
| ៥ | អភិបាល ស្រុក-ខ័ណ្ឌ | ៥០០ ០០០ ៛ | ៥៣៨ ០០០ ៛ | ៥៧៨ ០០០ ៛ | ៦២១ ០០០ ៛ | ៦៦៦ ០០០ ៛ |

**មាត្រា ៤.-**

ប្រធានអង្គភាព ដែលមានរចនាសម្ព័ន្ធក្នុងក្រសួង-ស្ថាប័ន និងស្មើនាយកដ្ឋាន ត្រូវទទួលបានប្រាក់បំណាច់មុខងារជាប្រធាននាយកដ្ឋាន ដូចមានចែងនៅក្នុងមាត្រា ៣ ។

## ជំពូកទី ៣
## ប្រាក់កំរៃគរុកោសល្យ

**មាត្រា ៥.-**

ប្រាក់កំរៃគរុកោសល្យ គឺជាប្រាក់បន្ថែមលើប្រាក់បំណាច់មុខងារប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការក្នុងវិស័យអប់រំ ហើយដែលបានឆ្លងកាត់ វគ្គបណ្តុះបណ្តាលគរុកោសល្យ ។

មាត្រា ៦.-

ប្រាក់កំរៃគុរុកោសល្យ ត្រូវផ្តល់ជូនទៅតាមក្របខ័ណ្ឌប្រភេទមន្ត្រីរាជការ ដូចខាងក្រោម :

| ល.រ | ក្របខ័ណ្ឌ | ប្រាក់កំរៃគុរុកោសល្យ |
|---|---|---|
| ១ | ប្រភេទ ក | ១២ ០០០រ |
| ២ | ប្រភេទ ខ | ១០ ០០០រ |
| ៣ | ប្រភេទ គ | ៨ ០០០រ |
| ៤ | ប្រភេទ ឃ | ៦ ០០០រ |

មាត្រា ៧.-

ការកែប្រែប្រាក់កំរៃគុរុកោសល្យ ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

មាត្រា ៨.-

មន្ត្រីរាជការឯកទេសផ្សេងៗ ដែលត្រូវបានឧទ្ទេសនាមដោយក្រសួង ស្ថាប័ន អោយបង្ហាត់បង្រៀនពេញពេល នៅតាមគ្រឹះស្ថានសិក្សានានារយៈពេលពេញ ១ឆ្នាំ ត្រូវទទួលបានប្រាក់កំរៃគុរុកោសល្យ ។

លិខិតឧទ្ទេសនាម ត្រូវធ្វើឡើង ១ឆ្នាំម្តងៗ ។

## ជំពូកទី ៤
## ប្រាក់បង្គ្រប់

មាត្រា ៩.-

មន្ត្រីរាជការដែលទទួលបានប្រាក់បៀវត្សថ្មី (បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ) ទាបជាងប្រាក់បៀវត្សចាស់ ត្រូវទទួលបានប្រាក់បង្គ្រប់ ដែលធានាមិនអោយទាបជាងប្រាក់បៀវត្សចាស់ ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

មាត្រា ១០.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ១២.-**

អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០២ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ១១

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៣៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំ រេ ច

***មាត្រា ១:***

បង្កើតគណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ ដែលមាន សមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២-ឯកឧត្តម សុក ស៊ីផាន់ណា | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣-ឯកឧត្តម ព្រុំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៤-ឯកឧត្តម ត្រាំ អ៊ីវតឹក | រដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៥-ឯកឧត្តម ថោង ខុន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៦-ឯកឧត្តម ចាន់ តុងអ៊ីវ | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| ៧-ឯកឧត្តម ធី យ៉ាវ | រដ្ឋលេខាធិការក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៨-ឯកឧត្តម អ៊ិត ប្រាំង | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៩-ឯកឧត្តម សូ វិចធំរ | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០-ឯកឧត្តម ចី ចាន់ផល | អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១១-ឯកឧត្តម សារ៉ាក់ ខាន់ | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ១២-លោកជំទាវ ស៊ុន សារ៉ាតឿន | អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៣-ឯកឧត្តម លាភ វណ្ណដេន | អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៤-លោក ជា វណ្ណដេត | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៥-ឯកឧត្តម អភិបាលខេត្ត រតនៈគិរី | | សមាជិក |
| ១៦-ឯកឧត្តម អភិបាលខេត្ត ស្ទឹងត្រែង | | សមាជិក |
| ១៧-ឯកឧត្តម អភិបាលខេត្ត ព្រះវិហារ | | សមាជិក |
| ១៨-លោក ឆេង សារឿន | អគ្គនាយករងបច្ចេកទេស នៃក្រសួងពាណិជ្ជកម្ម | ជាលេខាធិការ |

***មាត្រា ២:***

គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ មានភារកិច្ចៈ

១- សិក្សាឯកសារ និងរៀបចំអនុសាសន៍ស្តីពីលទ្ធភាព និងគំរូផែនការអភិវឌ្ឍន៍រួមគ្នា នៃតំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ

២- ធ្វើជាដៃគូចរចាជាមួយភាគី វៀតណាម-ឡាវ-ថៃ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ

៣- រៀបចំសេចក្ដីព្រាងកិច្ចព្រមព្រៀង ក្របខ័ណ្ឌស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ

៤- រៀបចំផែនការសកម្មភាពសំរាប់អនុវត្តន៍កិច្ចព្រមព្រៀងក្នុងក្របខ័ណ្ឌនេះ

៥- រៀបចំកម្មវិធី និងគំរោងវិនិយោគអាទិភាព ដើម្បីជំរុញការអនុវត្តន៍កិច្ចព្រមព្រៀងក្របខ័ណ្ឌ នៃតំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ

៦- សំរបសំរួលការងារជាមួយបណ្ដាក្រសួង-ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ

៧- ទំនាក់ទំនង និងស្វែងរកធនធានហិរញ្ញវត្ថុ ពីអ្នកផ្ដល់ជំនួយ និងផ្នែកឯកជនទាំងក្នុងប្រទេស និងក្រៅប្រទេស សំរាប់ធ្វើការសិក្សាស្រាវជ្រាវ និងអនុវត្តន៍កម្មវិធី និងគំរោងអាទិភាព

៨- ពង្រឹងការឯកភាពគ្នា ក្នុងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌប្រទេសអាស៊ាន

៩- បំពេញការងារដទៃទៀត តាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ

១០-គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ ត្រូវរាយការណ៍អំពីលទ្ធផលការងារខាងលើ ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសំរេច ។

## មាត្រា ៣ :

គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ អាចប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម រាល់លិខិតផ្លូវការរបស់ខ្លួន និងមានថវិកាសំរាប់ការងាររបស់ខ្លួន ដែលធ្វើជាមួយនិងគណនីរបស់ក្រសួងពាណិជ្ជកម្ម ។

សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

## មាត្រា ៤:

គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ នេះ មានលេខាធិការដ្ឋាន ដែលមានទីស្នាក់ការនៅទីស្ដីការក្រសួងពាណិជ្ជកម្ម ។ លេខាធិការដ្ឋាននេះត្រូវដឹកនាំដោយលេខាធិការមួយរូប និងជំនួយការមួយចំនួន តាមការចាំបាច់ ។ មន្ត្រីជំនួយការ ក្នុងលេខាធិការដ្ឋាននេះ ជាមន្ត្រីរបស់ក្រសួងពាណិជ្ជកម្ម ឬជាមន្ត្រីក្របខ័ណ្ឌ ដែលអាចស្នើសុំ ពីក្រសួង ស្ថាប័ននានា របស់រាជរដ្ឋាភិបាល ។

**មាត្រា ៥ :**

លេខាធិការដ្ឋានមាន ភារកិច្ចដូចតទៅ:

១- សំរបសំរួលដំណើរប្រព្រឹត្តទៅរបស់គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ មានជាអាទិ៍ ការរៀបចំផែនការការងារ ការរៀបចំកិច្ចប្រជុំ និងរបៀបវារៈនៃអង្គប្រជុំ របស់គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ

២- សំរបសំរួល និងទំនាក់ទំនងការងារជាមួយបណ្តាក្រសួង ដែលជាសមាជិកគណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ និងជាមួយបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ ដទៃទៀត

៣- ជាដៃគូចរចា កិច្ចបច្ចេកទេសជាមួយភាគី វៀតណាម ឡាវ និង ថៃ

៤- បំពេញការងារដទៃទៀត តាមការណែនាំរបស់ប្រធានគណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍ តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ ។

**មាត្រា ៦.**

ចំពោះមុខគណៈកម្មការនេះ ត្រូវបង្កើតក្រុមការងារបួនក្រុមគឺ:

- ក្រុមការងារពាណិជ្ជកម្ម
- ក្រុមការងារសាធារណៈការ និងដឹកជញ្ជូន
- ក្រុមការងារទេសចរណ៍
- និងក្រុមការងារឧស្សាហកម្មរ៉ែ-ថាមពល ។

គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ អាចបង្កើតក្រុមការងារ បន្ថែមទៀតបើយល់ឃើញថាចាំបាច់ ។

**មាត្រា ៧.**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

*មាត្រា ៨.*

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង សាមីខ្លួនដែលមានចែងក្នុងមាត្រា១ និងអភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី១៧ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ចម ប្រសិទ្ធ**

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៨

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩៥ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនឧកញ៉ា **ម៉ុត គឹមស៊ាន** ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការចូលរួមស្តារ និងកសាងវិស័យសេដ្ឋកិច្ច និងសិក្សាធិការជាតិ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោក **ឧន់ គន្ធី** នាយកវិទ្យាស្ថានគ្រប់គ្រង និង សេដ្ឋកិច្ចខេត្តបាត់ដំបង ដែលមានស្នាដៃល្អ ក្នុងការដឹកនាំកសាង និង គ្រប់គ្រងវិទ្យាស្ថានអោយមានដំណើរការល្អប្រសើរ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...១៩៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនមន្ត្រី ០៣ រូប តំណាងអង្គការ ស្បៀងអាហារពិភពលោក ដែលបានខិតខំស្វែងរក ជំនួយមកជួយកសាងផ្លូវលំ ០៩ ខ្សែ ក្នុងស្រុកកញ្ច្រៀច ខេត្តព្រៃវែង ចំណាយអស់អង្ករ ៥៣១.២៥៦ តោន មានតំលៃជាទឹកប្រាក់ ១៣២.៨១៤ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ÷

១-លោក **ឡៅ សុខារម្ម**

២-លោក **អ៊ុំ សុឆ្នី**

៣-លោក **ច្រឹង គឹមសួរ**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ........១៩៨ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ស ម្រេ ច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនឥស្សរជនចំនួន ០៦ រូប ដែលមានស្នាដៃល្អ និង គុណបំណាច់ដ៏ខ្ពង់ខ្ពស់ ក្នុងការរួមចំណែក ស្តារ និង កសាងសេដ្ឋកិច្ចជាតិកម្ពុជា ដូចមាននាមខាងក្រោម ÷

១ - លោក **ណូរីតាដា ម៉ូរីតា** ( Noritada Morita ) អតីតប្រធាននាយកដ្ឋានកម្មវិធីប្រទេសអាស៊ីនៃធនាគារអភិវឌ្ឍន៍អាស៊ី ( ADB )

២ - លោក **រ៉ាម៉ាណាថាន់ ណាតារ៉ាហ្សាន់** ( Ramanathan Natarajan ) អតីតឧត្តមទិប្រឹក្សា UNDP ទទួលបន្ទុកអាស៊ី អមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( CDC ) អតីតតំណាងធនាគារពិភពលោក ( WB ) នៅកម្ពុជា

៣ - លោក **ហាម៉ាឌី ហាមឌី** ( Hamadi Hamdi ) អតីតទីប្រឹក្សាជាន់ខ្ពស់មកពី UNDP អមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( CDC )

៤ - លោក **ព្យែហ្សា ដូលម៉ូ** ( Piazza d'Olmo ) អតីតទីប្រឹក្សាជាន់ខ្ពស់ផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ មកពីសហគមន៍អឺរ៉ុប ( EU ) អមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៥ - លោក **ឆាលស្ស ម៉ាទីម័រ** ( Charles Martimor ) អតីតទីប្រឹក្សាជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុសាធារណៈមកពីប្រទេសបារាំង អមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៦ - លោក **ងូវ បេង អ៊ាម** ( Ngau Beng Eam) អតីតទីប្រឹក្សាជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុសាធារណៈមកពីប្រទេសបារាំង អមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...១៩៩...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## ស ំ រេ ច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនអ្នកស្រី **Chantal de GHAISNE de BOURMONT** នាយិការង នាយកដ្ឋានសហប្រតិបត្តិការយោធា និងការពារ និង ជានាយិការង សហប្រតិបត្តិការ ក្រសួងការពារជាតិបារាំង ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការពង្រឹងទំនាក់ទំនងមិត្តភាព និង កិច្ចសហប្រតិបត្តិការកម្ពុជា - បារាំង ព្រមទាំងជួយកសាង និង អភិវឌ្ឍន៍ កងយោធពលខេមរភូមិន្ទ ទទួលបានលទ្ធផលល្អប្រសើរ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៥៧.០០.អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកវរសេនីយ៍ឯក Warren James Whiting សេនានុព័ន្ធអមស្ថានទូតញូវហ្សេឡង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អ ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការមិត្តភាព រវាងកងទ័ពប្រទេសទាំងពីរ កម្ពុជា - ញូវហ្សេឡង់ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួង ការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៥០១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគម និង សប្បុរសជនជប៉ុន ដែលបានធ្វើអំណោយអគារសិក្សា និងបង្គន់អនាម័យ ជូនសាលាបឋមសិក្សាព្រៃព្រែក និង សាលាបឋមសិក្សាពោន ស្រុករមាសហែក ខេត្តស្វាយរៀង ដូចមានខាងក្រោម ÷

១ - សមាគម GEDATSU - KAI ថវិកា ២៦.០០០ USD

២ - លោក NORIKO SUGITA ថវិកា ២៥.៦១០,៩២ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ២០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ខាវ៉ាហ្គីជី ម៉ាសាហ៊ីរ៉ូ** សប្បុរសជនជប៉ុន ដែលបានធ្វើអំណោយ អគារសិក្សាថ្មី ០១ ខ្នង និង ជួសជុល ០១ ខ្នង ជូនសាលាបឋមសិក្សាពញាឮ ស្រុកពញាឮ ខេត្តកណ្តាល ចំណាយអស់ទឹកប្រាក់ ៣៥.០០០ USD ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី១០ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៧០៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ថៃ ទីណា** សប្បុរសជនទៅទីក្រុងភ្នំពេញ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាងសមិទ្ធផលផ្សេងៗ ក្នុងវត្តសំព័រ ឃុំត្រពាំងសាលាខាង-លិច ស្រុកបន្ទាយមាស ខេត្តកំពត ចំណាយអស់ថវិកាចំនួន ២៥.៥៦០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១០៤ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **សេនា** ជូនមន្ត្រី ០២ រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច ជាតិ ដូចមាននាមខាងក្រោម ៖

១-ឯកឧត្តម **ចិន យន** ប្រធានរតនាគារជាតិ

២-ឯកឧត្តម **ឌុល គឿន** ប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច ក្រសួងមហាផ្ទៃ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៤០៥...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## ស ំ រ េ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រី ចំនួន ១៧ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញការងារបំរើ ជាតិ មាតុភូមិ ដូចមាននាមខាងក្រោម ÷

| | | | |
|---|---|---|---|
| ១- លោក | **ហ៊ីវ** | **សុវណ្ណ** | អនុប្រធានទី ១ រតនាគារជាតិ |
| ២-លោក | **មាស** | **ប៊ុនថន** | អនុប្រធានរតនាគារជាតិ |
| ៣-លោក | **ឆាយ** | **ឧុធ** | ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៤-លោក | **ចាន់** | **ស៊ុំ** | អនុប្រធាននាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៥-លោក | **គង់** | **សារ៉ា** | ប្រធាននាយកដ្ឋាន នៃក្រសួង កិច្ចការនារី និងអតីតយុទ្ធជន |
| ៦-លោក | **សោម** | **ឧត្តារ** | មន្ត្រីគយ |
| ៧-លោក | **ស្រី** | **សាមិត្ត** | ប្រធានការិយាល័យរតនាគារជាតិ |
| ៨-លោក | **អ៊ី** | **ឈាង** | ប្រធានការិយាល័យឃ្លាំងរតនាគារជាតិ |
| ៩-លោក | **កែ** | **ប៊ុនឡេង** | ប្រធានរតនាគាររាជធានីភ្នំពេញ |

១០-លោក **យឹម សេងគ្រី** អនុប្រធានរតនាគាររាជធានីភ្នំពេញ

១១-លោក **ហ៊ូ ហ៊ាន** អនុប្រធានរតនាគាររាជធានីភ្នំពេញ

១២-លោក **ខឹន ចាយ** អនុប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ

១៣-លោក **ហួរ ឡាមុនី** ជំនួយការឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី

១៤-លោក **ជា ចន្ថា** អនុប្រធាននាយកដ្ឋាន ផែនការ ហិរញ្ញកិច្ច នៃក្រសួងមហាផ្ទៃ

១៥-លោក **សួស សារុន** អនុប្រធាននាយកដ្ឋាន ផ្សព្វផ្សាយ នៃក្រសួងមហាផ្ទៃ

១៦- លោក **ជឹម សុខា** អនុប្រធានការិ.ត្រួតពិនិត្យនៃនាយកដ្ឋានហិរញ្ញកិច្ច

១៧-លោក **នួច សំអឿន** អនុប្រធានមន្ទីរ អប់រំ ខេត្តកណ្តាល

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ[illegible] ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៧៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការទប់ស្កាត់ការធ្វើអន្តោប្រវេសន៍ខុសច្បាប់ នៅខេត្តរតនគិរី មណ្ឌលគិរី និងខេត្តក្រចេះ

✧✧✧✧✧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីអន្តោប្រវេសន៍
- យោងតាមសំណើរបស់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ៈ** ត្រូវបានបង្កើតគណៈកម្មការទប់ស្កាត់ការធ្វើអន្តោប្រវេសន៍ខុសច្បាប់នៅខេត្តរតនគិរី មណ្ឌលគិរី និងខេត្តក្រចេះ ដែលតាមខេត្តនិមួយៗមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១-**ឯកឧត្តមអភិបាលខេត្ត** | ជាប្រធាន |
| ២-**លោកស្នងការនគរបាលខេត្ត** | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៣-**លោកមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត** | ជាសមាជិក |
| ៤-**លោកមេបញ្ជាការវរៈការពារព្រំដែនប្រចាំខេត្ត** | ជាសមាជិក |

**ប្រការ២ៈ** គណៈកម្មការទប់ស្កាត់ការធ្វើអន្តោប្រវេសន៍ខុសច្បាប់នេះមានភារកិច្ច៖

- ដឹកនាំអនុវត្តអោយបានត្រឹមត្រូវតាមច្បាប់អន្តោប្រវេសន៍

-ចាត់វិធានការគ្រប់បែបយ៉ាង រក្សាការពារខ្សែបន្ទាត់ព្រំដែនទប់ស្កាត់រាល់ការជ្រៀតចូលដោយខុសច្បាប់របស់ជនបរទេសទាំងឡាយ មកក្នុងព្រះរាជាណាចក្រកម្ពុជា ។

-ជនបរទេសដែលជ្រៀតចូលខុសច្បាប់តាមច្រកទ្វារណា ឬរបៀងណាត្រូវចាត់បញ្ជូនចេញទៅវិញតាមច្រកទ្វារ និងរបៀងនោះវិញ ។

-ត្រូវចាត់វិធានការសហប្រតិបត្តិការជាមួយអាជ្ញាធរប្រទេសជិតខាង ដែលមានព្រំប្រទល់ជាប់គ្នា ដើម្បីមានផែនការទប់ស្កាត់រាល់ការចេញ ចូលដោយខុសច្បាប់ មកក្នុងប្រទេសទាំងសងខាង ។

-រាល់ករណីដែលមិនស្ថិតក្នុងសមត្ថកិច្ចដោះស្រាយរបស់ខេត្ត ត្រូវរាយការណ៍ជាបន្ទាន់មកក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ដើម្បីមានវិធានការដោះស្រាយ ។

-រៀងរាល់ខែគណៈកម្មការត្រូវរាយការណ៍អំពីស្ថានភាពទូទៅ និងលទ្ធផលកិច្ចប្រតិបត្តិការ ព្រមទាំងទិសដៅវិធានការជូនក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

**ប្រការ៣:** គណៈកម្មការទប់ស្កាត់ការធ្វើអន្តោប្រវេសន៍ខុសច្បាប់ មានសិទ្ធិប្រើប្រាស់កម្លាំង និងមធ្យោបាយដែលមានស្រាប់ស្ថិតក្រោមឱវាទ ដើម្បីដោះស្រាយការងារដែលមានការពាក់ព័ន្ធ ។

-សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីចាំបាច់ប្រធានគណៈកម្មការមានសិទ្ធចាត់សមាជិកម្នាក់អោយដឹកនាំការងារចុះត្រួតពិនិត្យជំនួស ។

**ប្រការ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ អគ្គនាយករដ្ឋបាល និងឯកឧត្តម អស់លោកក្នុងប្រការ១ ត្រូវអនុវត្តសេចក្ដីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០២

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

**កន្លែងទទួល:**

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ដូចប្រការ១ និងប្រការ៤
-ឯកសារ-កាលប្បវត្តិ